# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

CAMBODIA WATCHDOG COUNCIL INTERNATIONAL

---

## សេចក្តីថ្លែងការណ៍

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សម្តែងការព្រួយបារម្ភជាខ្លាំង ចំពោះរាជរដ្ឋាភិបាល រដ្ឋសភា និងក្រុម-ប្រឹក្សាធម្មនុញ្ញ ជំរុញដំណើរការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញថ្មី យ៉ាងប្រញាប់ប្រញាល់ ខណៈពេលស្ថានភាពប្រទេសកម្ពុជា កំពុងមានវិបត្តិនយោបាយ វិស័យសេដ្ឋកិច្ចធ្លាក់ចុះ ទំនិញទីផ្សារឡើងថ្លៃ ប្រេងឥន្ធនៈក៏ឡើងថ្លៃ និង ភាពអយុត្តិធម៌សង្គមក៏កើនឡើងជាដើម។ល។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** យល់ឃើញថា រដ្ឋធម្មនុញ្ញបច្ចុប្បន្ន មានតម្លៃគ្រប់គ្រាន់ក្នុងការធានាប្រក្រតីភាព និងយន្តការការងាររបស់ស្ថាប័នជាតិ។ ដូច្នេះពុំគួរមានភាពចាំបាច់ណាមួយ ធ្វើការកែប្រែរដ្ឋធម្មនុញ្ញដែលមជ្ឈដ្ឋានសាធារណៈមើលឃើញថា «កែរដ្ឋធម្មនុញ្ញ ដើម្បីបំពេញបំណងរបស់អ្នកកាន់អំណាច»។

ការកែមាត្រា ១២៥ថ្មី បង្ហាញថាជាការបើកផ្លូវឲ្យមានការចាត់តាំងនាយករដ្ឋមន្ត្រីថ្មី និងបង្កើតរដ្ឋាភិបាលថ្មី នៅពេលណាក៏បាន តាមការចង់បានរបស់បក្សកាន់អំណាច។ ការកែមាត្រា ១១៩ថ្មី ធ្វើឡើងជាការបង្កភាពងាយស្រួលក្នុងការចាត់តាំងបុគ្គលណាម្នាក់ជា នាយករដ្ឋមន្ត្រីថ្មី តាមរយៈការប្រគល់អំណាចឲ្យគណបក្សនយោបាយ ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ជាអ្នកស្នើឲ្យ ព្រះមហាក្សត្រ ចាត់តាំង នាយករដ្ឋមន្ត្រីថ្មី។ ទង្វើនោះគឺជាការកាត់បន្ថយអំណាចរដ្ឋសភា ដែលផ្ទុយពីគោលការណ៍សភានិយម ក្នុងរបបប្រជាធិបតេយ្យសេរី។ ការកែមាត្រាដទៃៗទៀត សុទ្ធតែបង្ហាញពីការការពារអំណាចរដ្ឋាភិបាលថ្មីមួយ ស្របតាមខ្លឹមសារនៃការកែប្រែ មាត្រា ១១៩ថ្មី និងមាត្រា ១២៥ថ្មី។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមអំពាវនាវរាជរដ្ឋាភិបាល រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាទម្លាក់ចោល នូវគម្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះជាបន្ទាន់។ ហើយគួរតែត្រូវដោះស្រាយបញ្ហាជាតិ ដែលកំពុងប្រឈមនៅចំពោះមុខ ជាអាទិភាព ដូចជា ការផ្សះផ្សានយោបាយជាតិ ការដោះស្រាយបញ្ហាសេដ្ឋកិច្ចធ្លាក់ចុះ ទំនិញទីផ្សារឡើងថ្លៃ ប្រេងឥន្ធនៈក៏ឡើងថ្លៃ និង ដោះស្រាយភាពអយុត្តិធម៌សង្គម ជូនពលរដ្ឋរងគ្រោះជាដើម។

ថ្ងៃពុធ៧កើត ខែអាសាឍ ឆ្នាំខាលចត្វាស័ក ព.ស ២៥៦៦

*រាជធានីភ្នំពេញ* ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២២

តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា